ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ..០.៥.២........អ.ស.ហ.ប្រ.ក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ
## ក្នុងវិស័យបរធនបាលកិច្ច

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច

- បានឃើញប្រកាសលេខ០០៦ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៧២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ១២ នៃប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ៦៣៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- យោងតាមការអនុម័តនៃសម័យប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃអចលនវត្ថុ ក្នុងវិស័យបរធនបាលកិច្ចពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្ម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច សំដៅធានាឱ្យបានសុក្រឹតភាពនៃតម្លៃបរធនបាលកិច្ច ដែលបានបង្កើត និងចុះបញ្ជីបរធនបាលកិច្ច។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពវាយតម្លៃអចលនវត្ថុក្នុងវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច÷



ល.

**ក្រុមហ៊ុនវាយតម្លៃ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណសេវាកម្មវាយតម្លៃពីនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ (ន.អ.ប.)។

**វិញ្ញាបនបត្រវិជ្ជាជីវៈ** សំដៅដល់លិខិតគតិយុត្តដែលចេញដោយ **ន.អ.ប.** ជូនរូបវន្តបុគ្គលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីប្រកបវិជ្ជាជីវៈជាអ្នកជំនាញវាយតម្លៃ។

**ស្តង់ដាវាយតម្លៃ (Valuation Standard)** សំដៅដល់ស្តង់ដាវាយតម្លៃដែលដាក់ឱ្យប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទទួលបានការទទួលស្គាល់ឱ្យប្រើប្រាស់ក្នុងការវាយតម្លៃ សម្រាប់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ។

**អ្នកជំនាញវាយតម្លៃ** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈពី **ន.អ.ប.** ដើម្បីផ្តល់សេវាកម្មវាយតម្លៃជូនអតិថិជន ក្នុងនាមក្រុមហ៊ុនវាយតម្លៃ។

**អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តដែលចេញដោយ **ន.អ.ប.** ដើម្បីអនុញ្ញាតឱ្យនីតិបុគ្គលណាមួយដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីប្រកបសេវាកម្មវាយតម្លៃ។

## ជំពូកទី២

## ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ

**ប្រការ៤.-**

ក្រុមហ៊ុនវាយតម្លៃដែលមានបំណងស្នើសុំការទទួលស្គាល់ពី **ន.ម.ឆ.** ត្រូវដាក់ពាក្យស្នើសុំទៅតាមទម្រង់ និងឯកសារភ្ជាប់ ដែលកំណត់ដោយ **ន.ម.ឆ.** ព្រមទាំងបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម÷

១- ទទួលបានអាជ្ញាបណ្ណពី **ន.អ.ប.**

២- បានបង្កើត និងមានធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងហោចណាស់ ២ (ពីរ) ឆ្នាំ គិតមកត្រឹមថ្ងៃដាក់ពាក្យស្នើសុំការទទួលស្គាល់

៣- មានអ្នកជំនាញវាយតម្លៃយ៉ាងតិចចំនួន ១ (មួយ) រូប ដែលអ្នកជំនាញវាយតម្លៃនោះ ត្រូវបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

**ប្រការ៥.-**

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ អ្នកជំនាញវាយតម្លៃត្រូវដាក់ពាក្យស្នើសុំមក **ន.ម.ឆ.** ទៅតាមទម្រង់ និងឯកសារភ្ជាប់ ដែលកំណត់ដោយ **ន.ម.ឆ.** ព្រមទាំងបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

១- មានវិញ្ញាបនបត្រវិជ្ជាជីវៈដែលចេញដោយ **ន.អ.ប.**

២- មានបទពិសោធន៍វាយតម្លៃក្នុងវិស័យអចលនទ្រព្យ យ៉ាងតិច ៣ (បី) ឆ្នាំ

៣- ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនវាយតម្លៃ

៤- ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ម.ឆ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឆ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពី

កាលបរិច្ឆេទដែល **ន.ម.ឆ.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ **ន.ម.ឆ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឆ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

**ប្រការ៦.-**

ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ មានសុពលភាពអនុលោមទៅតាមសុពលភាពនៃអាជ្ញាបណ្ណពី **ន.អ.ម.** គិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ។

**ប្រការ៧.-**

ក្រុមហ៊ុនវាយតម្លៃត្រូវដាក់ពាក្យស្នើសុំបន្តការទទួលស្គាល់មក **ន.ម.ឆ.** ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ឆ.** ឱ្យបានយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទការទទួលស្គាល់អស់សុពលភាព។

អ្នកជំនាញវាយតម្លៃត្រូវដាក់ពាក្យស្នើសុំបន្តការទទួលស្គាល់មក **ន.ម.ឆ.** ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ឆ.** ឱ្យបានយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទការទទួលស្គាល់គុណវុឌ្ឍិអស់សុពលភាព។

**ប្រការ៨.-**

**ន.ម.ឆ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធការទទួលស្គាល់ ឬបន្តការទទួលស្គាល់ ដូចមានចែងក្នុងប្រការ៧ ក្នុងរយៈពេលយ៉ាងយូរ ២១ (ម្ភៃមួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ឆ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ៩.-**

បរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល និងបុគ្គលដទៃទៀត ដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃដែលទទួលបានការទទួលស្គាល់ និងផ្សព្វផ្សាយជាផ្លូវការដោយ **ន.ម.ឆ.**។

## ជំពូកទី៣

## ភារកិច្ចរបស់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃដែលទទួលបានការទទួលស្គាល់

**ប្រការ១០.-**

ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដាដែលជាលក្ខខណ្ឌតម្រូវអាជ្ញាបណ្ណពី **ន.អ.ម.** ដូចខាងក្រោម÷

១- ស្តង់ដាវាយតម្លៃ

២- គោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាវាយតម្លៃជាធរមាន



ស.

៣-ក្រមសីលធម៌វិជ្ជាជីវៈអ្នកជំនាញវាយតម្លៃ និង

៤-ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ១១.-**

ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ធ.** ត្រូវរៀបចំរបាយការណ៍វាយតម្លៃនៅពេលវាយតម្លៃអចលនវត្ថុនៃបរធនបាលកិច្ច ដោយបង្ហាញនូវព័ត៌មានអប្បបរមាដូចខាងក្រោម÷

១-ប្រភព និងប្រភេទនៃព័ត៌មាន

២-ការជ្រើសរើសវិធីសាស្ត្រវាយតម្លៃ

៣-វិធីសាស្ត្រប្រមូលទិន្នន័យ

៤-ហេតុផលនៃការជ្រើសរើសបរធនប្រៀបធៀប

៥-ការសន្មតផ្សេងៗ ដែលបានប្រើប្រាស់សម្រាប់ការវាយតម្លៃ

៦-ស្ថានភាពសេដ្ឋកិច្ច ផ្លូវច្បាប់ ការប្រើប្រាស់បរធនរងការវាយតម្លៃ និងស្ថានភាពផ្សេងទៀត ដែលជះឥទ្ធិពលទៅលើតម្លៃរបស់បរធនរងការវាយតម្លៃ

៧-លក្ខខណ្ឌនៃការដោះដូរបរធនរងការវាយតម្លៃ

៨-លក្ខខណ្ឌហិរញ្ញវត្ថុរបស់បរធនរងការវាយតម្លៃ

៩-លក្ខខណ្ឌទីផ្សារនៃបរធនរងការវាយតម្លៃ

១០-នីតិវិធី និងយន្តការ សម្រាប់ការត្រួតពិនិត្យបរធនរងការវាយតម្លៃនៅនឹងកន្លែង

១១-ការផ្ទៀងផ្ទាត់នូវការវាយតម្លៃបរធនរងការវាយតម្លៃដែលបានប្រើ និង

១២-កត្តាចម្បងផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃបរធនរងការវាយតម្លៃ។

**ប្រការ១២.-**

ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ធ.** ត្រូវរាយការណ៍ជូន **ន.ម.ធ.** ក្នុងករណីដូចខាងក្រោម÷

១-មានការស្នើសុំដោយ **ន.ម.ធ.** ឱ្យពន្យល់ ឬផ្តល់ព័ត៌មាន និងទិន្នន័យ ដែលទាក់ទងនឹងសកម្មភាពវាយតម្លៃអចលនវត្ថុ

២-រកឃើញថា បរធនជាអចលនវត្ថុកំពុងត្រូវបានវាយតម្លៃ មិនបានបំពេញបែបបទតាមច្បាប់

៣-មានការសុំឈប់ ការបញ្ឈប់ ឬការផ្អាកផ្តល់សេវាកម្មវាយតម្លៃ ឬ

៤-រកឃើញថា បរធនរងការវាយតម្លៃមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។



ម.

**ប្រការ១៣.-**

កិច្ចសន្យាវាយតម្លៃជាមួយបរធនបាល ត្រូវមានចែងអំពីសិទ្ធិរបស់ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ក្នុងការផ្តល់ព័ត៌មាន ឬផ្តល់របាយការណ៍វាយតម្លៃជូន **និ.ម.ធ.**។

**ប្រការ១៤.-**

ក្រុមហ៊ុនវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **និ.ម.ធ.** ត្រូវផ្តល់របាយការណ៍ប្រតិបត្តិការប្រចាំឆ្នាំ ក្នុងវិស័យបរធនបាលកិច្ចមក **និ.ម.ធ.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ ឬតាមការកំណត់របស់ **និ.ម.ធ.**។

**ប្រការ១៥.-**

ករណី **និ.ម.ធ.** តម្រូវឱ្យក្រុមហ៊ុនវាយតម្លៃពិនិត្យឡើងវិញ ចំពោះចំណុចមួយចំនួន ដែលមិនមានភាពច្បាស់លាស់ ក្រុមហ៊ុនវាយតម្លៃ ត្រូវអនុវត្តតាមការស្នើសុំរបស់ **និ.ម.ធ.** ដោយផ្តល់ជូនឱ្យបានឆាប់នូវព័ត៌មាន និងឯកសារបន្ថែម។

## ជំពូកទី៤
## កម្រៃ

**ប្រការ១៦.-**

ក្រុមហ៊ុនវាយតម្លៃត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០ (ពីររយពាន់) រៀល និងថ្លៃការទទួលស្គាល់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុង១ (មួយ) ឆ្នាំ។

**ប្រការ១៧.-**

អ្នកជំនាញវាយតម្លៃត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល និងថ្លៃការទទួលស្គាល់ចំនួន ២០០.០០០ (ពីររយពាន់) រៀល ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ១៨.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត ដែលបានបង់មក **និ.ម.ធ.** អនុលោមតាមប្រកាសនេះ មិនត្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**ប្រការ១៩.-**

ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌនៃការទទួលស្គាល់ដូចមាន

ចែងក្នុងប្រកាសនេះ ត្រូវទទួលរងនូវវិធានការរដ្ឋបាល ដូចខាងក្រោម÷

-ការព្រមាន

-ការដឹកនាំកែតម្រង់

-ការដាក់កំហិតលើការទទួលស្គាល់

-ការព្យួរការទទួលស្គាល់ និង

-ការដកហូតការទទួលស្គាល់។

**ប្រការ២០.-**

**ន.ប.ឆ.** អាចព្យួរការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ក្នុងករណីដូចខាងក្រោម÷

១-មិនអនុវត្តស្តង់ដាវាយតម្លៃដូចចែងក្នុងប្រការ១០ នៃប្រកាសនេះ

២-រកឃើញថា ព័ត៌មានដែលមាននៅក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬលាក់បាំងព័ត៌មាន

៣-មានបណ្តឹងបដិសេធចំពោះលទ្ធផលវាយតម្លៃ ឬ

៤-វិញ្ញាបនបត្រវិជ្ជាជីវៈ ឬអាជ្ញាបណ្ណចេញដោយ **ន.អ.ម.** ត្រូវបានព្យួរ។

**ប្រការ២១.-**

**ន.ប.ឆ.** អាចដកហូតការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ក្នុងករណីដូចខាងក្រោម÷

១-ចំពោះក្រុមហ៊ុនវាយតម្លៃ

ក- អាជ្ញាបណ្ណពី **ន.អ.ម.** ត្រូវបានដកហូត

ខ-ផុតកាលវសាននៃការព្យួរដូចដែលមានចែងក្នុងប្រការ២០ នៃប្រកាសនេះ ដោយមូលហេតុនៃការព្យួររបស់ក្រុមហ៊ុនវាយតម្លៃនៅតែមិនទាន់បានដោះស្រាយ ឬ

គ-ក្រុមហ៊ុនវាយតម្លៃបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការបន្លំព័ត៌មានវាយតម្លៃ ឬច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត ឬមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

២-ចំពោះអ្នកជំនាញវាយតម្លៃ

ក-វិញ្ញាបនបត្រវិជ្ជាជីវៈចេញដោយ **ន.អ.ម.** ត្រូវបានដកហូត

ខ-ផុតកាលវសាន្តនៃការព្យួរដូចដែលមានចែងក្នុងប្រការ២០ នៃប្រកាសនេះ ដោយមូលហេតុនៃការព្យួររបស់អ្នកជំនាញវាយតម្លៃនៅតែមិនទាន់បានដោះស្រាយ ឬ

គ-អ្នកជំនាញវាយតម្លៃបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការបន្លំព័ត៌មានវាយតម្លៃ ឬច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត ឬមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ប្រការ២២.-**

ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ដែលត្រូវបានព្យួរ ឬដកហូតការទទួលស្គាល់ដូចមានចែងក្នុងប្រការ២០ និងប្រការ២១ នៃប្រកាសនេះ ត្រូវបញ្ឈប់សកម្មភាពធុរកិច្ចក្នុងវិស័យបរធនបាលកិច្ច ចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរពី **ន.ម.ធ.**។ ក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ដែលត្រូវបានព្យួរសកម្មភាពធុរកិច្ច អាចចាប់ផ្តើមដំណើរការឡើងវិញបាន បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពី **ន.ម.ធ.**។

**ប្រការ២៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ដែលប្រព្រឹត្តល្មើសនឹងប្រការ៧ ឬប្រការ១៤ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ៤០.០០០.០០០ (សែសិបលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះក្រុមហ៊ុនវាយតម្លៃ ឬអ្នកជំនាញវាយតម្លៃ ដែលប្រព្រឹត្តល្មើសនឹងចំណុចទី២ ឬចំណុចទី៤ ក្នុងប្រការ១២ នៃប្រកាសនេះ។

**ប្រការ២៤.-**

បែបបទ នីតិវិធី និងការប្តឹងតវ៉ាចំពោះវិធានការរដ្ឋបាល និងការផាកពិន័យ ដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ដោយប្រកាសរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច។

**ប្រការ២៥.-**

វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២៦.-**

**ន.ម.ធ.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច និងដល់សាធារណជន។

**ប្រការ២៧.-**

អគ្គនាយកនៃ **ន.ម.ធ.** ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យ **ន.ម.ធ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើតខែ កត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២៧

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ